# THE CONJUNCTION

392. Read the following sentences:--

៣៩២. ចូរអានឃ្លាខាងក្រោម:

1. God made the country *and* man made the town.

ព្រះបង្កើតប្រទេស ហើយមនុស្សបង្កើតទីក្រុង។

2. Our hoard is little; *but* out hearts are great.

អ្វីដែលយើងសន្សំទុកមានតិច តែចិត្តរបស់យើងធំណាស់។

Hoard = អ្វីដែលយើងសន្សំទុក (ជាពិសេសលុយ)

3. She must weep, *or* she will die.

គាត់ត្រូវតែយំ បើមិនអញ្ចឹងទេងាប់ហើយ។

Weep = យំ

Or (conj) = or else, else = បើមិនដូច្នេះទេ/បើមិនអញ្ចឹងទេ

4. Two *and* two made four. ពីរបូកពីរត្រូវជាបួន។

In 1, 2, and 3 the Conjunctions join together two sentences.

នៅក្នុងលេខ១, លេខ២ និងលេខ៣ Conjunction ភ្ជាប់ឃ្លាពីរ។

In 4, the Conjunction joins together two words only. [See #393]

នៅក្នុងឃ្លាទី៤ Conjunction ភ្ជាប់តែពាក្យពីរប៉ុណ្ណោះ។ [ចូរមើលលេខ៣៩៣]

Def.—A Conjunction is a word which merely *joins* together sentences, and sometimes ~~(joins together)~~ words.

និយមន័យ--Conjunction គឺជាពាក្យមួយដែលគ្រាន់តែភ្ជាប់ឃ្លា(និងឃ្លា)ហើយជួនកាលពាក្យ(និងពាក្យ)។

Merely (adv) = simply, only = គ្រាន់តែ

393. Conjunctions joins together sentences and often make them more compact; thus,

៣៩៣. Conjuncitons ភ្ជាប់ឃ្លានិងឃ្លា ហើយជាញឹកញាប់វាធ្វើឲ្យឃ្លានោះខ្លី ដូចជា

Compact = ហាប់, (ឃ្លា) ខ្លី

'Balu *and* Vithal are good bowels' is a short way of saying 'Balu is a good bowler *and* Vithal is a good bowler'

«Balu និង Vithal គឺជាអ្នកពូកែបោះប៊ូល» គឺជាការបំព្រួញខ្លីនៃការនិយាយថា Balu is a good bowler and Vithal is a good bowler។

| | | | |
|---|---|---|---|
| 'Balu ~~(is a good bowler)~~ and | Vith al | is ↓ *ar* | a good bowler '. ↓ good |

www.salarean.com

| | | e | bowler*s*. |
|---|---|---|---|

Balu and Vithal are good bowlers.

So, 'The man is poor, *but* honest' is a contracted way of saying 'The man is poor, *but* he is honest'.

ដូច្នេះឃ្លាដែលថា The man is poor, *but* honest.' គឺជារបៀបបំព្រួញខ្លីនៃការនិយាយថា 'The man is poor, *but* he is honest'។

Noun + and + Noun + Plural Verb
(Noun + and + Noun = Subject)

The man is poor (ADJ), but (Conj) ~~(he is)~~ honest (ADJ).

*****នៅក្នុងភាសាអង់គ្លេសពាក្យប្រើច្រំដែលគេលុបចោលគឺពាក្យ he ជំនួសឲ្យពាក្យ man ហើយពាក្យ is ប្រើរួចហើយនៅខាងមុខ ដូច្នេះត្រូវលុបចោល។

Ellipsis = របៀបដែលគេលុបពាក្យច្រំដែលចោល។

eg. Sok *has* two *cows* and Soa (~~*has*~~) three (~~*cows*~~).

...... which merely *joins together* sentences, and sometimes (~~*joins together*~~) words.

Sometimes, however, the Conjunction *and* joins words only; as,

ប៉ុន្តែជួនកាល Conjunction *and* ភ្ជាប់តែពាក្យទេ ដូចជា

ពាក្យ *And* ជា apposition ឲ្យពាក្យ Conjunction។

Two (N) *and* two (N) make four. (ឃ្លានេះមិនអាចផ្តាច់ជាពីរឃ្លាបានដោយសារពាក្យ four)

Hari *and* Rama are brother. (ឃ្លានេះមិនអាចផ្តាច់ជាពីរឃ្លាបានដោយសារពាក្យ borther)

Hari & Rama គឺជាបងប្អូន។

Hari *and* Rama came home together. (មិនអាចផ្តាច់ជាពីរបានដោយសារពាក្យ together)

Such sentences cannot be resolved in two sentences.

ឃ្លាបែបនេះមិនអាចបំបែកជាពីរឃ្លាបានទេ។

To resolve sth into sth = បែងចែក......ជា......

...... cannot be resolved in/into two sentences.

...... មិនអាចបំបែកជាពីរឃ្លាបានទេ។

394. Conjunctions must be carefully distinguished from Relative Pronouns, Relative Adverbs, and Prepositions, which are also connecting words.

៣៩៤. Conjunctions ត្រូវតែធ្វើការបែងចែកដោយប្រុងប្រយ័ត្នឲ្យដាច់ស្រឡះពី Ralative Pronouns, Relative Adverbs និង Prepositions ដែលពាក្យទាំងអស់នេះក៏ជាពាក្យសំរាប់ភ្ជាប់ឃ្លាដែរ។

www.salarean.com

To distinguish A from B = បែងចែក A ឲ្យដាច់ស្រឡះពី B / បែងចេក A និង B

To distinguish between A and B = បែងចែកថាតើមួយណាជា A មួយណាជា B

Connecting words = ពាក្យសំរាប់ភ្ជាប់

1. This is the house ___. Jack built ~~it~~ which (the house).[Relative Pronoun]

This is the house (N) + which Jack built (Relative Clause (modify to noun *house*)) . [NP]

Conjunction មានតួនាទីភ្ជាប់ពាក្យនិងពាក្យ ឃ្លានិងឃ្លា។

Relative Pronoun មានតួនាទីជំនួស Noun ហើយភ្ជាប់ឃ្លា។

2. This is the place. He (S) was murdered (Verb) ~~here /there~~ which (ADV). (Relative Adverb)

This is the place (Noun) + *where* (ADV) he (S) was murdered (Verb) [Relative Clause] . [Noun Phrase]

*****នៅពេលយើងយកឃ្លាទាំងពីរឲ្យទៅជាឃ្លាតែមួយ

យើងមើលតាមតួនាទីពាក្យដែលទាក់ទង គ្នា។ ពាក្យ here ឬ there ទាក់ទងនិងពាក្យ the place ប៉ុន្តែ part of speech វាជា ADV ដូច្នេះយើងមិនអាចយក ពាក្យដែលមានតួនាទីជា ADV មកជំនួសបានទេ។ ដូច្នេះគេយកពាក្យ Where ដែលមានតួនាទីជា ADV មកជំនួស ពា here/there ។ នៅពេលជំនួសពាក្យ ហើយវាត្រូវឈរនៅមុខឃ្លាឬដើមឃ្លា ហើយទើបយកឃ្លាទាំងមូលទៅដាក់ជិត Anticident របស់វា ប៉ុន្តែដោយសារវានៅជិត Anticident របស់វាស្រាប់ យើងមិនចាំបាច់លើកម្តងទៀតទេឡើយ។

***ដូច្នេះតួនាទីរបស់ Where ជា Adverb បំពេញន័យឲ្យ was murdered ហើយភ្ជាប់ឃ្លា This is the place និងឃ្លា where he was murdered។

***អញ្ចឹងបានគេហៅឈ្មោះវាថា Relative Adverb ព្រោះវាដើតួនាទីដូច Ralative Pronoun ភ្ជាប់ឃ្លា ហើយ មានតួនាទីជា Adverb។

3. Take this *and* give *that*. (Conjunction)

យកអានេះទៅហើយឲ្យអានោះមក។

In sentence 1, the Relative Pronoun *that* refers to the noun *house*, and also joins the two parts of the sentence.

នៅក្នុងឃ្លាទី១ Relative Pronoun: *that* និយាយសំដៅទៅរក Noun *house* ហើយវាភ្ជាប់ផ្នែកទាំងពីររបស់ ឃ្លា។

In sentence 2, the Relative Adverb *where* modifies the verb *was murdered* and also joins the two parts of the sentence.

www.salarean.com

នៅក្នុងឃ្លាទី២ Relative Adverb *where* បំពេញន័យឲ្យ Verb *was murdered* ហើយវាភ្ជាប់ផ្នែកទាំងពីរ របស់ឃ្លា។

In sentence 3, the Conjunction *and* simply joins the two parts of the sentence; *it does no other work*.

នៅក្នុងឃ្លាទី៣ Conjunction *and* គ្រាន់តែភ្ជាប់ផ្នែកទាំងពីររបស់ឃ្លាតែប៉ុណ្ណោះ វាអត់មានធ្វើកិច្ចការអ្វី ផ្សេងទេ។

It will thus be seen that—

ដូច្នេះគេនឹងបានឃើញថា--

Relative Pronoun and Relative Adverbs also join; but they do more.

Relative Pronoun និង Relative Adverbs ក៏ភ្ជាប់ឃ្លាដែរ ប៉ុន្តែវាធ្វើកិច្ចការច្រើនជាងនេះទៅទៀត។

Conjunctions merely join: they do no other work.

Conjunctions គ្រាន់តែភ្ជាប់ទេ: វាអត់មានកិច្ចការអ្វីផ្សេងទេ។

Observe that a Preposition also joins two words, but it does more; it governs a noun or pronoun;as,

ចូរសង្កេតថា Preposition ក៏ភ្ជាប់ពាក្យពីរដែរ ប៉ុន្តែវាធ្វើកិច្ចការលើសពីនេះទៅទៀត វាថែមទាំងកំណត់ទំរង់ របស់ Noun ឬ Pronoun ទៀតផង ដូចជា

He sat $\underbrace{\text{beside}}_{\text{Prep}}$ Rama. គាត់អង្គុយជិត Rama។

1. Beside ភ្ជាប់ He និង Rama។

2. Beside កំណត់ទំរង់របស់ពាក្យ Rama ឲ្យដឹងថា Rama ជា Object របស់វា (beside)

He stood *behind* me.

1. Behind ភ្ជាប់ He stood និង me.

2. Behind កំណត់ទំរង់របស់ពាក្យ me ថាតើពាក្យ me ជាអ្វី។ ពាក្យ me ជា Object របស់ Behind។

395. Some Conjuctions are used in pairs; as,

៣៩៥. Conjunctions មួយចំនួនត្រូវបានគេប្រើជាគូ ដូចជា

Either—or.

=អ្វី១ឬអ្វី១/នេះក្តីនេះក្តី/បើមិនអានេះក៏អានោះ

*Either* take it *or* leave it.

=បើមិនយកទុកទៅ (=យកក៏បានមិនយកក៏បាន)

Neither—nor. (ជាឃ្លាបដិសេធរបស់ Either—or) = មិនទាំងអ្វី១......មិនទាំងអ្វី១

It is *neither* $\underbrace{\text{useful}}_{\text{ADJ}}$ *nor* $\underbrace{\text{ornamental}}_{\textit{ADJ}}$.

www.salarean.com

វាអត់ប្រយោជន៍ហើយអត់អាចលំអរអ្វីបានទៀត។

Ornamental = (សំរាប់តុងតែង)លំអរ

Both—and. = ទាំងអ្វី១.....ទាំងអ្វី១

We *both* $\underbrace{\text{love}}_{\text{Verb}}$ *and* $\underbrace{\text{honour}}_{\text{Verb}}$ him.

យើងស្រលាញ់គាត់ផងហើយផ្តល់កិត្តិយសឲ្យគាត់ផង។

| | | |
|---|---|---|
| (ជាទូទៅការប្រើប្រាស់ | eithher - -or.....<br>neither - -nor.....<br>both.....and.....<br>notonly.....but also..... | គឺដូចគ្នា។) |

eg. I speak both $\underbrace{\text{English}}_{\text{N}}$ and $\underbrace{\text{French}}_{\text{N}}$.

ខ្ញុំនិយាយទាំងភាសាអង់គ្លេសទាំងភាសាបារាំង។

We both $\underbrace{\text{love}}_{\text{V}}$ and $\underbrace{\text{honour}}_{\text{V}}$ him.

ពួកយើងស្រលាញ់គាត់ផងហើយផ្តល់កិត្តិយសដល់គាត់ផង។

They gave us both $\underbrace{\text{material}}_{ADJ}$ and $\underbrace{\text{moral}}_{\text{ADJ}}$ assistance.

ពួកគេបានផ្តល់ឲ្យយើងនូវការជួយឧបត្ថម្ភទាំងសំភារៈនិងស្មារតី។

They help us both $\underbrace{\text{materially}}_{ADV}$ and $\underbrace{\text{morally}}_{\text{ADV}}$.

ពួកគេជួយឧបត្ថម្ភដល់យើងទាំងខាងសំភារៈទាំងខាងស្មារតី។

Assistance (n) = ការជួយឧបត្ថម្ភ

Material assistance = ការជួយឧបត្ថម្ភខាងសំភារៈ

Moral assistance = ការជួយឧបត្ថម្ភខាងស្មារតី

Either $\underbrace{\text{take}}_{\text{imperative}}$ or $\underbrace{\text{leave}}_{\text{imperative}}$ it.

Either $\underbrace{\text{you pay me back}}_{Sentence}$ or $\underbrace{\text{you go to prison}}_{Sentence}$.

អ្នកឯងសងខ្ញុំវិញក៏បាន ចូលគុកក៏បាន។ (មានជំរើសតែមួយទេ)

បើមិនសងលុយខ្ញុំចូលគុកក៏បាន។

I saw a group of students *either* going to class *or* coming back from it.

ខ្ញុំឃើញសិស្សមួយក្រុមបើមិនទៅរៀនក៏ត្រឡប់មកពីរៀនដែរ។

to see sb doing sth (បញ្ចូលConjunction រួចហើយភ្ជាប់ឃ្លាពីរ)

Though—yet. (rare in current English)

= ទោះបីជា (កម្រប្រើណាស់នៅក្នុងភាសាអង់គ្លេសសព្វថ្ងៃ)

*Though* he is suffering much pain, *yet* he does not complain.

ទោះបីជាគាត់ទទួលរងនូវការឈឺចាប់ច្រើនប៉ុណ្ណាក៏ដោយក៏គាត់មិនត្អូញត្អែដែរ។

To suffer pain = ទទួលរងការឈឺចាប់

www.salarean.com

Whether....... or not
Whether or not........ = Noun Clause = ថាតើ.......ដែរឬអត់

Whether......or (not) = Adverb clause = ទោះបីជា

eg. We will go ahead (VI) whether they agree or not (ADV Clause).

ពួកយើងនឹងបន្តទៅមុខទៀតទោះបីជាពួកគេព្រមឬមិនព្រមក៏ដោយ។

I don't know (vt) whether they agree or not (Noun Clause).

ខ្ញុំមិនដឹងថាតើពួកគេព្រមឬក៏អត់នោះទេ។

To go ahead = បន្ត

I do not care *whether* you go *or* stay.

care about sth

ខ្ញុំមិនខ្វល់ទេទោះបីជា/ថាតើពួកគេទៅឬក៏នៅក៏ដោយ។

Not only—but also. = មិនត្រឹមតែ.....ថែមទាំង, មិនត្រឹមតែប៉ុណ្ណោះ......ថែមទាំងទៀតផង

He is *not only* foolish (Adj), *but also* obstinate.

គាត់មិនត្រឹមតែភ្លីវភ្លើបុ៉ណ្ណឹងទេ ថែមទាំងក្បាលរឹងទៀតផង។

Obstinate = ចចេស, ក្បាលរឹង

He is *not only* foolish, *but* (~~also~~) obstinate. (also អាចលុបចោលបាន)

He is *not only* foolish. He is *also* obstinate. (ផ្តាច់ជាពីរឃ្លាហើយលុប but)

He is *not only* foolish. He is obstinate. (ផ្តាច់ជាពីរហើយលុប but also)

He (S) is (V) *not only* foolish. He is *but also* obstinate.

*Not only* is (V) he (S) foolish, *but also* obstinate. (ត្រឡប់ subject)

*****នៅពេលយើងយក Not only មកដាក់ដើមឃ្លាត្រូវត្រឡប់ subject ។

-ចំពោះ Verb *to be* ត្រឡប់ធម្មតា/ត្រឡប់ខ្លួនឯង

-ចំពោះ Verb ធម្មតា/ordinary verb ប្រើ verb ជំនួយ Do។

Conjunctions which are thus used in pairs are called *Correlative Conjunctions* or merely *Correlatives*.

Conjunctions ដែលគេប្រើជាគូដូច្នេះ គេហៅឈ្មោះវាថា Correlative Conjunctions ឬគ្រាន់តែហៅថា Corrlative ក៏បាន។

Thus (adv) = ដូច្នេះ

396. When Conjunctions are used as Correlatives, each of the correlated words should be placed *immediately before* the words to be connected; as,

www.salarean.com

៣៩៦. នៅពេលដែល Conjunctions ត្រូវគេយកមកប្រើជា Correlatives ពាក្យនីមួយៗដែលទាក់ទងគ្នាគួរ តែដាក់នៅជាប់ពីខាងមុខពាក្យដែលត្រូវតភ្ជាប់។

Correlated = ទាក់ទងគ្នាទៅវិញទៅមក

Place immediately before = ដាក់នៅជាប់ពីខាងមុខ (ទីតាំងពាក្យ)

Immediately before = (ពេលវេលា) មុនពេលភ្លាម

He visited *not only* Agra (N) *but also* Delhi (N).

គាត់មិនគ្រាន់តែទៅលេង Agra ប៉ុណ្ណោះទេតែថែមទាំង Delhi ទៀតផង។

(NOT) He *not only* visited Agra, *but also* Delhi.

397. We use many compound expressoions as Conjunctions; these are called Compound Conjunctions.

៣៩៧. យើងប្រើសំនួនវោហាស័ព្ទដែលផ្សំគ្នាជាច្រើនជា Conjunction ទាំងអស់នេះគេហៅឈ្មោះ ថា Compound Conjunctions ។

......... in order that / so that + Clause = ......ដើម្បី (Adverbial Clause of Purpose)

Adverbial Clause of purpose = កិរិយាវិសេសដែលប្រាប់ពីគោលបំណង

in order that / so that | ជា Conjunction នាំមុខ Adverb Clause។

The notice was published *in order that* all might know the facts.

សេចក្ដីជូនដំណឹងនេះត្រូវបានគេបោះពុម្ពផ្សាយដើម្បីឲ្យអ្នកទាំងអស់គ្នាបានដឹងពីការពិត។

...... on condition that + clause (Adv of condition) = if = ក្នុងលក្ខខ័ណ្ឌដែលថា......

I will forgive you *on condition that* you do not repeat the offence.

ខ្ញុំនឹងអភ័យទោសឲ្យអ្នកក្នុងលក្ខខ័ណ្ឌដែលអ្នកមិនប្រព្រឹត្តបទល្មើសសារជាថ្មី។

offence (n) = បទល្មើស

to repeat the offence = ការប្រព្រឹត្តបទល្មើសម្ដងទៀត

Even if + clause (Adv of concession/contrast) = ទោះបីជា

Adv of concession/contrast (កិរិយាវិសេសដែលបង្ហាញពីន័យផ្ទុយគ្នា)=គឺជា ADVដែលបង្ហាញពី ហេតុការណ៍ដែលកើតឡើងផ្ទុយពីហេតុការណ៍នៅក្នុង Main Clause។

Such an act would not be kind *even if* it were just.

អំពើបែបហ្នឹងមិនមែនជាអំពើល្អទេទោះបីជាអំពើបែបហ្នឹងវាត្រឹមត្រូវក៏ដោយ។

Kind = ល្អ, ចិត្តល្អ

Just = ត្រឹមត្រូវ, យុត្តិធម៌

So that = in order that (adv of purpose)

So that + Subject + a modal + infinitive

www.salarean.com

...... in order that in all *might* know the facts.

...... ដើម្បីឲ្យអ្នកទាំងអស់គ្នាដឹងពីការពិត។

...... so that he *should* not go hungry.

...... ដើម្បីកុំឲ្យគាត់ឃ្លាន។

go = become (goជា link verb)

to go hungry = to become hungry

Go + Adjective

He saved some bread *so that* he should not go hungry on the morrow.

គាត់ទុកនំប៉័ងខ្លះដើម្បីកុំឲ្យគាត់ឃ្លាននៅថ្ងៃស្អែកឡើង។

on the morrow (ADV) = នៅថ្ងៃក្រោយ(ថ្ងៃស្អែក)

Save = រក្សា, ទុក

| | |
|---|---|
| Provided (that)<br>Providing (that)<br>Adv Clause of Condition | = if = បើ, ប្រសិនបើ |

You can borrow the book *provided that* you return it soon.

អ្នកអាចខ្ចីសៀវភៅនេះបានប្រសិនបើអ្នកឆាប់សងវិញ។

| | |
|---|---|
| As though<br>As if<br>ADV of manner | + Clause = ហាក់ដូចជា |

| | | | | |
|---|---|---|---|---|
| It | is<br>seems<br>looks | as if<br>as<br>though | ......<br>...... | = វាហាក់ដូចជា......<br>=<br>វាមើលទៅដូចជា...... |

He walks *as though* he is slightly lame.

គាត់ដើរហាក់ដូចជាគាត់ហ្នឹងពិកាបន្តិច។

Lame = ពិកា

He is lame in the left leg. គាត់ពិការជើងឆ្វេង។

Slightly = បន្តិច

Inasmuch as = in that = ត្រង់ថា

eg. She was guilty, *inasmuch as* she know what others were planning.

គាត់មានទោសត្រង់ថាគាត់ដឹងពីអ្វីដែលអ្នកដទៃរៀបចំផែនការ។

(ឧ. ដឹងថាគេធ្វើអំពើខុសច្បាប់តែអត់រាយការណ៍ នាំឲ្យមានទោស។)

The UN bore responsibility for the war *inasmuch as* it was (=war was....) waged to enforce UN resolutions.

www.salarean.com

អង្គការសហប្រជាជាតិទទួលខុសត្រូវចំពោះសង្គ្រាមនៅត្រង់ថាសង្គ្រាមនោះត្រូវបានធ្វើឡើង ដើម្បីអនុវត្ត សេចក្ដីសំរេចរបស់អង្គការសហប្រជាជាតិ។

To bear responsibility for sth = ទទួលខុសត្រូវចំពោះ......

To wage war = ធ្វើសង្គ្រាម

To enforce (vt) = អនុវត្ត (ឧ. ច្បាប់, បំរាមគោចរ, សេចក្ដីសំរេចចិត្ត ។ល។)

I must refuse your request, *inasmuch as* I believe it unreasonable.

ខ្ញុំត្រូវតែបដិសេធសំណើរបស់អ្នក ត្រង់ថាខ្ញុំជឿថាសំណើហ្នឹងវាមិនសមហេតុផល។

To refuse sb's request = បដិសេធសំណើរបស់នរណាម្នាក់

To believe + noun + adj/participle

...... as I believe the request (*Noun*) unreasonable (*adj(C)*).

ជឿថាសំណើនេះគឺមិនសមហេតុផល។

...... as I believe (~~that~~) the request (*S*) (~~is~~) unreasonable (*ADJ(C)*).

*****ប៉ុន្តែនៅពេលយើងប្រើ that clause នៅខាងក្រោយ believe ហើយ verb នៅក្នុង that clause គឺ verb to be។ to be គេលុបចោលហើយត្រូវលុប that ចោលដែរ។

| ...... as I | believe | the request | unreasonable. |
|---|---|---|---|
| | V | *obj* | *Adj* (C of obj) |

As well as = ព្រមទាំង

Sok (S) as well as + Singular Verb (*Verb*) (អាស្រ័យលើ Noun *Sok*)

Sok and Soa (*S*) + Plural Verb (*Verb*).

Rama *as well as* Givind *was* present there.

Rama ព្រមទាំង Govind មានវត្តមាននៅទីនោះ។

As soon as = នៅពេលដែល.....ភ្លាម

He took off his coat *as soon as* he entered the house.

គាត់ដោះអាវគាត់ចេញភ្លាមនៅពេលដែលគាត់ចូលមកដល់ផ្ទះភ្លាម។

To take off = ដោះចេញ

As if = ហាក់ដូចជា

He looks *as if* he were weary. គាត់មើលទៅហាក់ដូចជាអស់កម្លាំងណាស់។

Weary = tire = ហត់, ហេវហត់, អស់កម្លាំង

www.salarean.com

## CLASS OF CONJUNCTIONS

398. As we shall see conjunctions are divided into two classes: Co-ordinating and Subordinating.

៣៩៨. ដូចយើងនឹងបានឃើញហើយថា Conjunctions ចែកជាពីរប្រភេទគឺ Co-ordinating Conjunction និង Subordinating Conjunction។

| | |
|---|---|
| ...... two class: | Co-ordinating and Subordinating. |

*Apposition ទៅ two class*

Read the sentence:

ចូរអានឃ្លានេះ

Bird fly *and* fish swim.

The sentence contains two *independent* statements or two statements of *equal rank* or important.

ឃ្លានេះមានឃ្លាឯករាជ្យពីរឬក៏ឃ្លាពីរដែលមានតំលៃស្មើគ្នាឬក៏ឃ្លាពីរដែលមានសារៈសំខាន់ដូចគ្នា។

rank = ឋានៈ, តំលៃ (វេយ្យាករណ៍)

equal = ស្មើគ្នា

of equal rank = ដែលមានតំលៃឬឋានៈស្មើគ្នា

of equal important = ដែលមានសារៈសំខាន់ដូចគ្នា

Hence the Conjunction joining together these two statements or clauses of *equal rank* is called a *Co-ordinating Congjunction* ['Co-ordinating' means of *equal rank*.]

ដូច្នេះ Conjunction ដែលភ្ជាប់ឃ្លាទាំងពីរនេះឬក៏ឃ្លាដែលមានតំលៃស្មើគ្នានេះ គេហៅឈ្មោះវាថា Co-ordinating Conjunction ['Conjunction' មានន័យថា មានតំលៃស្មើគ្នា។]

Def.—A Co-ordinating Conjunction joins together clauses of equal rank.

និយមន័យ--Co-ordinating Conjunction ភ្ជាប់ឃ្លាដែលមានតំលៃស្មើគ្នា។

399. The chief Co-ordinating Conjunctions are:--

៣៩៩. Co-ordinating Conjunction សំខាន់ៗមាន:

And, but, for (=ដោយសារ), nor (=មិន.....ដែរ), also , either...or, neither...nor.

A: I don't understand.

B: Nor / Neither | do I. (=I *do not* understand *either*.) ខ្ញុំក៏មិនយល់ដែរ។

A: I *go* there. B: I *go* there *too*.

www.salarean.com

A: I *don't go* there.   B: I *don't go* there *either.*

400. Co-ordinating Conjunctions are of four kinds:

៤០០. Co-ordinating Conjunctions មាន៤ប្រភេទ:

(1) *Cumulative* or *Copulative* which merely *add* one statement to another; as,

(១) Cumulative ឬ Copulative ដែលគ្រាន់តែបន្ថែមការនិយាយអះអាងមួយទៅលើការនិយាយអះអាងមួយ ទៀត ដូចជា

We carved not a line, *and* we raised not a stone.

យើងអត់មានឆ្លាក់អ្វីមួយបន្ទាត់ទេហើយយើងមិនមានលើកដុំថ្មអីមួយដុំដែរទេ។

to carve = ឆ្លាក់

to raise = លើក

(2) *Adversative* which express opposition or *contrast* between two statements; as,

(២) Adversative ដែលបញ្ជាក់ពីការផ្ទុយគ្នារវាងការនិយាយអះអាងពីរ ដូចជា

He is slow, *but* he is sure.   គាត់យឺតតែគាត់ច្បាស់ប្រាកដ។

I wan annoyed, *still* I keep quiet.   ខ្ញុំខឹងតែយ៉ាងណាក៏ដោយខ្ញុំនៅស្ងៀមស្ងាត់។

Still (adversative) = ទោះបីជាយ៉ាងណាក៏ដោយ

I would come; *only that* I am engaged.   (កុំអី)ខ្ញុំមកហើយទាស់តែ/ប៉ុន្តែ ខ្ញុំរវល់។

I would offer to babysit, *only* I'm going out myself.

(កុំអី)ខ្ញុំស្ម័គ្រចិត្តមើលក្មេងហើយទាស់តែខ្ញុំត្រូវចេញក្រៅខ្លួនឯងដែរ។

to babysit = មើលក្មេង

to offer to do sth = មានបំណងឬស្ម័គ្រចិត្តធ្វើអ្វី១

(Would = បញ្ជាក់ពីន័យមិនពិត)

He was all right; *only* he was fatigued.   គាត់មិនអីទេ   ទាស់តែ/ប៉ុន្តែ គាត់អស់កំលាំងបន្តិច។

(3) Disjunctive or Alternative which express a *choice* between two alternatives; as,

(៣) (Co-ordinating Conjunctions ហៅឈ្មោះថា) Disjunctive ឬ Alternative ដែលបញ្ជាក់ពីជម្រើសរវាង ជម្រើសពីរ ដូចជា

She must weep, *or* she will die.   គាត់ត្រូវតែយំបើមិនអញ្ចឹងទេគាត់នឹងស្លាប់។

*Either* he is mad, *or* he feign madness.   គាត់បើមិនឆ្កួតក៏ធ្វើពុតជាឆ្កួតដែរ។

| | |
|---|---|
| to feign<br>to pretend | madness = ធ្វើពុតជាឆ្កួត |

*Neither* a borrower (~~be~~), *nor* a lender be. (Proverb)

ចូរកុំធ្វើជាអ្នកខ្ចីគេ ហើយក៏កុំឲ្យគេខ្ចី។ (ពីព្រោះលុយវាធ្វើឲ្យបាត់បង់មិត្តផងលុយផង)

They toil not, *neither* do they spin.   ពួកគេមិនខិតខំធ្វើការហើយក៏មិនខិតខំរវៃដែរ។

www.salarean.com

to toil = ខិតខំធ្វើការ

to spin = ខា/រវៃអំបោះ

They do not toil. They do *not* spin, *either*.

They do not toil. Nor do (V) they (S) spin. (ត្រឡប់ Subject)

They do not toil, nor do they spin.

I will not agree. I will not oppose.

I will not agree, *nor* will (V) I (S) oppose.

ខ្ញុំមិនយល់ព្រមទេហើយក៏មិនបដិសេធប្រឆាំង/បដិសេធដែរ។

Nor = មិនដែរ = not either

I will quickly, *else* you will not overtake him.

ដើរឲ្យលឿន បើមិនអញ្ចឹងទេមិនអាចវ៉ាគាត់បានទេ។

To overtake sb = វ៉ា sb

(4) Illlative which express an *interence*; as,

(៤) (Co-ordinating Conjunction មានឈ្មោះថា) Illative ដែលបញ្ជាក់ពីការសន្និដ្ឋាន ដូចជា

Something certainly fellin: *for* I heard a splash.

ពិតជាមានអ្វីធ្លាក់ចូលហើយ ព្រោះខ្ញុំឮសំលេងផ្លូក។

Splash = លាន់ឮសំលេងផ្លូក (នៅពេលមានវត្ថុអ្វី១ធ្លាក់ចូលទៅក្នុងទឹក)

to splash water = បាចទឹក

for = ពីព្រោះ

All precautions must have been neglected, *for* the plague spread rapidly.

គេប្រាកដជាភ្លេចវិធានការបង្ការគ្រប់បែបយ៉ាងទាំងអស់ហើយមើលទៅ បានជាជំងឺហ្នឹងរាលដាល លឿនម្លឹង។

Precaution (n) = ការបង្ការ

Plague = ជំងឺឆ្លង

Spread = (ជំងឺ) រាលដាល

Rapidly (adv) = យ៉ាងលឿន, យ៉ាងរហ័ស

For = ដោយសារ, ពីព្រោះ, បានជា

Must = ធ្វេសប្រហែស , បំភ្លេច

Must (Certainty = ភាពប្រាកដ)

Present Certainty: Must + Present infinitive

eg. You must be hungry. អ្នកប្រាកដជាឃ្លានហើយ។

You must be sleepy. អ្នកប្រាកដជាងងុយដេកហើយ។

www.salarean.com

Past Certainty: Must + Perfect infinitive

eg. You must have been very angry. អ្នកប្រាកដជាខឹងខ្លាំងហើយ។

401. Any of the Co-ordinating Conjunctions, with the exception of *or*, *nor*, may be omitted and its place (may be) taken by a comma, semi-colon, or colon; as,

៤០១. Cor-ordinating Conjunction ណាមួយក៏ដោយក្នុងចំណោម Co-ordinating Conjunction ខាងលើ លើកលែងតែពាក្យ or និង nor ចេញ អាចលុបចោល ហើយកន្លែងរបស់វាអាចជំនួសដោយ comma, semi-colon, ឬក៏ colon ដូចជា

with the exception of…… = លើកលែងតែ

…… may be omitted and its place (~~may be~~) taken (Past Participle) by……

Rama went out to play; Hari stayed in to work.

402. Read the sentence:

៤០២. ចូរអានឃ្លានេះ

I read the paper *beause* it interests me. ខ្ញុំអានកាសែតពីព្រោះវាធ្វើឲ្យខ្ញុំចាប់អារម្មណ៍។

The sentence contains two statements or clauses one of which, 'beause it interests me' is *dependent* on the other. Hence the Conjunction introducing the *dependent* or *subordinate* clause is called a *Subordinating Conjunction*.

ឃ្លានេះមានពីរឃ្លា(ទីមួយគឺ I read the paper និងទីពីរ It interests me.) ដែលមួយក្នុងចំណោមឃ្លាពីរនេះ គឺឃ្លា "beause it interests me." គឺវាពឹងផ្អែកលើឃ្លាមួយទៀត។ ដូច្នេះ Conjunction ដែលផ្តើមឃ្លាមិនឯករាជ្យឬឃ្លា រណបនេះគេហៅឈ្មោះថា Subordinating Cinjunction ។

*Def.*—A Subordinating Conjunction joins a clause to another on which it depends for its full meaning.

និយមន័យ--Subordinating Conjunction ភ្ជាប់ Clause មួយទៅ Clause មួយទៀតដែលវាពឹងផ្អែកដើម្បីឲ្យ មានន័យពេញលេញ។




(ប្រាប់ពីមូលហេតុថាតើហេតុអ្វីបានជាអាន។)

403. The chief Subordinating Conjunctions are:--

៤០៣. Subordinating Conjunction សំខាន់ៗរួមមាន:

After, because, if, that, though, although, till, before, unless, as, when, where, while.

www.salarean.com

## Complex Sentence

Main Clause + Sub - clause

(1) Noun Clause: that

(2) Adjective/Relative Clause: that, where

(3) Adverb clause:

- (1) Time: after, till until, before, as, when, while, since, as long as,
- (2) Place: where, when, wither, whence,
- (3) Manner: as,
- (4) Cause/reason: because, as, since
- (5) Result:
- (6) Purpose: lest,
- (7) Condition: if, unless,
- (8) Concession: though, although, unless,
- (9) Comparison: than,

Unless: លុះណាតែ, បើមិន

As: ពីព្រោះ, នៅពេលដែល, ទោះបីជា, ដូចដែល

I don't know (vt) where he lives (Obj (Noun Clause)).

I will go (vi) where I want (ADV(Adverb Clause)). ខ្ញុំនឹងទៅកន្លែងណាដែលខ្ញុំចង់ទៅ។

This is the place (N) where he was born (ADJ Clause).

1. *After* the shower was over the sun shone out again (Main Clause).

បន្ទាប់ពីភ្លៀងរលឹមរាំងទៅ ព្រះអាទិត្យក៏បញ្ចេញរស្មីជាថ្មី។

The sun shone out again *after* the shower was over.

Shower = ភ្លៀងរលឹម

To shine out = បញ្ចេញរស្មី, ចាំង

To be over = ចប់, (ភ្លៀង) រាំង

CLAUSE CONJUNCTION CLAUSE

CONJUNCTION CLAUSE + CLAUSE

2. A book's a book (Main Clause), although (Adv of concession), there is nothing in it (Sub-clause).

សៀវភៅគឺជាសៀវភៅទោះបីជាមិនមានអ្វីនៅខាងក្នុងក៏ដោយ។

www.salarean.com

A boo$\underbrace{\text{k's}}_{=is}$ a book.

Book's = Book is (ព្រោះវាជា main clause)

*****Adverb of concession វាបង្ហាញពីពត៌មានផ្ទុយគ្នា។

*****Clause ដែលនាំមុខដោយ although ជាទូទៅវាបង្ហាញពីឧបសគ្គដែលកើតឡើងតែឧបសគ្គ នោះមិនអាចរារាំងអំពើនៅក្នុង Main Clause បានទេ។

3. $\underbrace{\text{As}}_{\text{Adv of reason}}$ he was not there, I spoke to his brother.

ដោយសារគាត់មិននៅទីនេះខ្ញុំក៏និយាយជាមួយបងប្អូនប្រុសគាត់ទៅ។

ADJ + $\underbrace{\text{AS}}_{\text{Concession}}$ + S + BE = ទោះបីជា

eg. Young as he is = Tough he is young. ទោះបីជាគាត់នៅក្មេងក៏ដោយ។

As he is young = Because he is young. ដោយសារគាត់នៅក្មេង។

4. He ran away *because* he was afraid. គាត់រត់ចេញទៅដោយសារតែគាត់ខ្លាច។

5. *Answer the first question* ***before*** you proceed further.

ចូរឆ្លើយសំណួរទីមួយសិនមុនពេលអ្នកបន្តទៅមុខទៀត។

To proceed = បន្ត

Further = ទៅមុខទៀត

6. Take heed $\underbrace{\text{ere it be too late}}_{\text{Adv Clause}}$. ចូរយកចិត្តទុកដាក់កុំឲ្យយឺតពេលទាន់/កុំឲ្យហួសពេល។

Heed (n) = ការយកចិត្តទុកដាក់

To heed (vt) = យកចិត្តទុកដាក់

To pay | heed / attention | to sth/doing sth = យកចិត្តទុកដាក់ចំពោះអ្វី១

*Ere = before*

heedless of late = យឺតពេល

…… before it is too late.

…… កុំឲ្យយឺតពេលទាន់/កុំឲ្យហួសពេល។

eg. You must take action before it is too late.

អ្នកឯងត្រូវតែចាត់វិធានការណ៍កុំឲ្យយឺតពេលទាន់។

7. $\underbrace{\text{Except}}_{\text{Conj}}$ ye repent, you shall likewise perish.

លើកលែងតែថាអ្នកមានការសោកស្តាយបើមិនអញ្ចឹងទេអ្នកទាំងអស់គ្នានឹងស្លាប់ក្នុងរបៀបដូចគ្នាអញ្ចឹងដែរ។

Except គេកម្រប្រើជា Conjunction។

Except គេនិយមប្រើជា Preposition។

www.salarean.com

Ye = You.

To repent = ស្តាយក្រោយ (ឧ. ធ្វើខុស)

Likewise (adv) = ដូចគ្នាអញ្ចឹងដែរ, តាមរបៀបដូចគ្នា

To perish (vi) = to be killed = ស្លាប់

Except (Conj) = លើកលែងតែថា

8. You will pass *if* you work hard. អ្នកនឹងប្រលងជាប់ប្រសិនបើអ្នកខំរៀន។

1. If + Present Simple + will + infinitive (First Condition)

2. If + Past Simple (Unreal Condition for the present) + would + Infinitive (Unreal result for the present) (Second Condition)

3. If + Past Perfect (Unreal Condition for the past) + would + have + pp (unreal result for the past) (Third Condition)

9. Sentinels were posted *lest* the camp should be taken by surprise (Adv Clause of purpose).

អ្នកយាមត្រូវបានគេដាក់តាមកន្លែងដើម្បីកុំឲ្យជុំរំហ្នឹងត្រូវគេវាយឆ្មក់។

Sentinel = អ្នកយាម

to post sentinels = ដាក់អ្នកយាម, ដាក់តាមប៉ុស្តិ៍ដែលត្រូវឈរតាម

lest (Conj) = so……that……not = ដើម្បីកុំឲ្យ

To take sb by surprise (Expression) = ធ្វើឲ្យ sb ភ្ញាក់ផ្អើល

Sb is teken by surprise = Sb មានការភ្ញាក់ផ្អើល

10. *Since* you say so, I must believe it.

ដោយហេតុថាអ្នកនិយាយអញ្ចឹងទៅហើយនោះខ្ញុំត្រូវតែជឿហើយ។

Since (Conj) = ចាប់តាំងពី (Time), ពីព្រោះ, ដោយហេតុថា (Cause)

11. Tell them *that* I will come. ចូរប្រាប់ពួកគេទៅថា ខ្ញុំនឹងមក។

To tell sb (Obj) that - clause (Obj (Noun Clause)).

12. He finished first though (Adv of concession) he began late.

គាត់ចប់មុនគេទោះបីជាគាត់ចាប់ផ្តើមយឺតជាងគេក៏ដោយ។

13. Will you wait *till* I return? តើអ្នកនឹងរង់ចាំដល់ខ្ញុំវិលត្រឡប់មកវិញបានទេ?

14. He will not pay *unless* he is compelled (Condition).

គាត់មិនសងទេទាល់តែបង្ខំ(បានបង់)។/ គាត់នឹងមិនសងទេបើគេមិនបង្ខំទេនោះ។

Unless (Conj) = លុះណាតែ, បើមិន (Adv of condition)

to compel = បង្ខំ

15. I waited for my friend *until* he came. ខ្ញុំរង់ចាំមិត្តរបស់ខ្ញុំរហូតដល់គាត់មក។

to wait for sb = រង់ចាំ sb

www.salarean.com

16. *When* I was younger (Adv clause of time), I thought so. កាលខ្ញុំនៅក្មេងជាងហ្នឹង ខ្ញុំគិតអញ្ចឹង។

17. I do not know whence he comes (Noun Clause (Obj of know)). ខ្ញុំមិនដឹងថាតើគាត់មកពីណាទេ។

Whence (Conj) = from place/where

18. He found his watch where he had left it (Adv Clause).

គាត់រកឃើញនាឡិកានៅកន្លែងដែលគាត់ទុក/ភ្លេចវា។

(Adverb clause ប្រាប់យើងឲ្យដឹងថាតើរកនាឡិកាឃើញនៅកន្លែងណា។)

eg. I left my watch in the room. ខ្ញុំភ្លេចនាឡិការបស់ខ្ញុំនៅក្នុងបន្ទប់។

***កាលណា where ជា Adjective Clause ពាក្យដែលវាជំនួសគឺពាក្យ(នាម) ប្រាប់ពីទីកន្លែង ដូចជា How, this place, this room។

19. I do not understand how it all happened (Noun Clause (Obj of understand)).

ខ្ញុំមិនយល់សោះមិនដឹងថាតើអ្វីទាំងអស់បានកើតឡើងដោយរបៀបណានោះទេ។

20. Make hay *while* the sun shines. (Proverb)

ហាសចំបើងទាន់មានថ្ងៃ។ ធ្វើស្រែទាន់ក្តៅដី។

hay (n) = ចំបើង / make hay = ហាលចំបើង

shine = រាំង, បញ្ចេញរស្មី

21. I shall go wither (=where) fency leads me.

ខ្ញុំនឹងទៅទីកន្លែងណាដែលចិត្តរបស់ខ្ញុំចង់ទៅ។

ខ្ញុំទៅកន្លែងណាដែលខ្ញុំចង់ទៅ/តាមចិត្តចង់ទៅ/ស្រេចតែហ្នឹងចិត្ត។

Wither = where

Fency (n) = គំនិតរវើរវាយ, ការចូលចិត្ត, ការចង់

22. I know not why he left us (Noun Clause). ខ្ញុំមិនដឹងថាតើហេតុអ្វីបានជាគាត់ចាកចេញពីពួកយើងនោះទេ។

404. The word *than* is also a Subordinating Conjunction:--

៤០៤. ពាក្យ than នេះក៏ជា Subordinating Conjunction ដែរ:

***ឃ្លាដែលភ្ជាប់ដោយ Coordinating Conjunction ហៅថា Compound Sentence។

***ឃ្លាដែលភ្ជាប់ដោយ Subordinating Conjunction ហៅថា Complex Sentence។ ព្រោះឃ្លាដែលនាំមុខដោយ Subordinating Conjunction ហៅថា Subordinator Clause។

Than (Adv clause of comparison)

…… as + Adj/Adv + as....... (Adv of comparison)

www.salarean.com

| | |
|---|---|
| ...... more ...... | than ...... |
| ...........er ...... | than ...... |
| | Adv of Comparison |

eg. He is tall. I am tall.

He is *as* tall *as* I am.
(as I am = Adv of Comparison (C) ADJ Phrase)

| | |
|---|---|
| He is taller than I ~~am~~.<br>He = S, is = V, taller = ADJ + than I = ADV → ADJ Phrase (C); I ↓ me | 1. S + V<br>2. S + V + Obj<br>3. S + V + Obj + Obj<br>4. S + V + Obj + C<br>*5. S + be + C* |

1. He is taller *than* I (am tall).

eg. He is as tall | than (I) ~~me~~. (than ↓ as; I ↓ me) He is tall than me.

He is taller | than (I) ~~me~~. (than ↓ than; I ↓ me) He is taller than me.

2. I like you *better than* he (likes you). ខ្ញុំចូលចិត្តអ្នកជាងគាត់ចូលចិត្តអ្នក។

I like you better than he likes you.

(ពាក្យ likes you គេមិនលុបចោលទេព្រោះធ្វើឲ្យប្តូរន័យរបស់ឃ្លា។)

*****ប៉ុន្តែបើយើងលុបពាក្យ likes you នោះវាទៅជា ៖

| | | | | |
|---|---|---|---|---|
| I like you | better than | *he* | ~~*likes you*~~. | (he : formal) |
| | | ↓ | | |
| | better than | *him*. | | (him : informal) |

www.salarean.com

I like you better *than* him.  OR:  I like you better *than* (~~I like~~) him.

មានន័យថា: ខ្ញុំចូលចិត្តអ្នកជាងខ្ញុំចូលចិត្តគាត់។ (ដូច្នេះវាប្តូរន័យ។)

3. I like you better *than* (I like) him.

4. Hari is more stupid (AP) .  Hari ហ្នឹងភ្លឺៗជាង

5. His brak is worse *than* his bite (is bad).  (Poverb)

ការព្រុះរបស់គាត់មិនអាក្រក់ដូចការខាំទេ។(គាត់អាក្រក់តែមាត់ទេ)

Bark = ការព្រុះ  Bite = ការខាំ

405. Subordinatong Conjunctions may be classified according to their meaning, as follows:--

៤០៥. Subordinating Conjunction អាចនឹងត្រូវគេចាត់ថ្នាក់យោងទៅតាមអត្ថន័យរបស់វាដូចខាងក្រោមនេះ

As follows = ដូចខាងក្រោមនេះ

Classify = ចាត់ថ្នាក់

According to = យោងទៅតាម

(1) Time

I would die *before* I lived.  ខ្ញុំនឹងងាប់មុនអាយុសឬងាប់មុខស្លាប់។

Sb/sth lies + ADV = ដេក/នៅ/ស្ថិតនៅ

Sb lies to sb = និយាយកុហល Sb

Sb lies about sth = និយាយកុហកអំពីអ្វី១

No nation can be perfectly well governed *till* it is competent to govern itself.

គ្មានប្រទេសណាអាចត្រូវគេគ្រប់គ្រងបានល្អឥតខ្ចោះនោះទេ  លុះណាតែ/ទាល់តែប្រទេសនោះមានសមត្ថភាពគ្រប់គ្រងខ្លួនឯង។

to govern = គ្រប់គ្រង

perfectly well = very well = យ៉ាងល្អឥតខ្ចោះ

competent (adj) = ដែលមានសមត្ថភាព, មានសមត្ថភាព

Many things have happened *since* I saw you.

អ្វីៗជាច្រើនបានកើតឡើងចាប់តាំងពីពេលដែលខ្ញុំជួបអ្នកមក។

I returned home *after* he had gone.

ខ្ញុំវិលត្រឡប់មកផ្ទះវិញបន្ទាប់ពីគាត់បានចេញទៅបាត់។

www.salarean.com

*Ere* he blew three note, there was a rustling.

នៅពេលមុនគាត់ផ្លុំណោតភ្លេងប៉ុហ្នឹងមានឮសូរសំលេងប្រស់ៗបន្តិច។

Note (n) = ណោតភ្លេង

Rustling (n) = ស្នូរប្រស់ៗ(ឧ. ក្រដាស់រឹង/លុយដុល្លារ/ស្លឹកឈើត្រូវខ្យល់)

Blow = ផ្លុំ

(2) Cause or Reason

My strength is as the strength often, *because* my heart is pure.

កំលាំងរបស់ខ្ញុំប្រៀបបីដូចជាកំលាំងរបស់មនុស្ស១០នាក់ឬកំលាំងរបស់មនុស្សអាយុ១០ ឆ្នាំ ពីព្រោះចិត្តរបស់ខ្ញុំ(គឺ)បរិសុទ្ធ។

Strength = កំលាំង

Pure (adj) = បរិសុទ្ធ

eg. Pure heart = ចិត្តបរិសុទ្ធ

Pure mind = គំនិតបរិសុទ្ធ

As (Prep.) = ដូច

*Since* you wish it, it shall be done.

ដោយសារអ្នកមានបំណងប្រាថ្នាចង់បានវាទៅហើយនោះវានឹងត្រូវគេធ្វើឡើង។

*As* he was not there, I spoke to his brother.

ដោយសារគាត់មិននៅទីនោះ ខ្ញុំក៏និយាយជាមួយបងប្អូនប្រុសគាត់។

He may enter, *as* he is a friend.

គាត់អាចចូលបាន ដោយសារគាត់ជាមិត្តភក្តិ។

(3) Purpose

(Purpose នាំមុខដោយ so that ប្រើជាមួយ Modal Verb ដូចជា may, should ហើយមិនអាចប្រែថា«ទេ»បានទេ ព្រោះវាជា Verb ជំនួយនៅក្នុង Purpose។)

We eat so *that* we may live. យើងហូបដើម្បីអាចរស់នៅ។

He held my hand *lest* I should fall. គាត់កាន់ដៃខ្ញុំដើម្បីកុំឲ្យខ្ញុំដួល។

(4) Result or Consequence

He was so tired (chief word; ADJ) *that* he would scacely stand (Sub-clause (Adv of result)) .
(He was so tired = Main Clause)

He was so tired that he could scacely stand. (so tired that he could scacely stand = ADJ Phrase)

គាត់ហេវហត់ខ្លាំងមែនទែនរហូតដល់គាត់ស្ទើរតែមិនអាចឈរបាន។

…… so + ADJ/ADV + that-clause (Adv of result)

……………………………. រហូតដល់/រហូតទាល់តែ

www.salarean.com

could scarcely = ស្ទើរតែមិន

could scaely stand = ស្ទើរតែមិនអាចឈរ

***នៅក្នុង Adv of result ជួនកាលគេសរសេរ so that ជាប់គ្នាដែរ។ ប៉ុន្តែ Adv of result ខុសពី Adv of purpose ជាទូទៅ (ជាទូទៅមិនមែនជានិច្ចទេ) មិនមាន Modal verbទេ។

S + V + C

(5) Condition (If, Unless)

Rama will go *if* Hari goes. Rama នឹងទៅប្រសិនបើ Hari ទៅ។

Grievances cannot be redressed *unless* they are know.

សារទុក្ខអាចកែតំរូវ/អាចប៉ះប៉ូវសងលុះណាតែគេដឹងអំពីសារទុកនោះ។

Grievances (n) = សារទុក្ខ (ការកើតទុកមិនសុខចិត្តផ្សេងៗ)

To redress (vt) = compensate, to make up for = ប៉ះប៉ូវសង/កែតម្រូវ

To air one's grivences = សំដែងនូវសារទុក្ខ/បញ្ចេញនូវសារទុក្ខ

Unless ជាលក្ខខ័ណ្ឌដាច់ខាត ន័យរបស់វាខ្លាំងជាង If not

UNLESS > IF NOT

(6) Concession [Adverb of concession គឺជាAdverb ដែលបង្ហាញពីន័យផ្ទុយគ្នារវាង main clause និង sub-clause ឬក៏ Adverb clause ដែលប្រាប់ពីឧបសគ្គដែលកើតឡើង តែឧបសគ្គហ្នឹងមិនអាចរារាំងអំពើនៅក្នុង Main clause បានទេ។

I will not see him, *thought* he comes. ខ្ញុំនឹងមិនជួបគាត់ទោះបីជាគាត់មកក៏ដោយ។

*Though* he slay me, *yet* will I trust him. ទោះបីជាគាត់សំលាប់ខ្ញុំក៏ដោយក៏ខ្ញុំទុកចិត្តគាត់ដែរ។

To slay = to kill = សំលាប់

Yet (adv) = ទោះបីជាយ៉ាងណាក៏ដោយ (កម្រប្រើ)

Although (conj) = ទោះបីជាយ៉ាងណាក៏ដោយ

A book's a book, *although* there's nothing in it.

សៀវភៅគឺសៀវភៅហើយទោះបីជាគ្មានអ្វីនៅក្នុងសៀវភៅនោះក៏ដោយ។

(7) Comparison [នាំមុខដោយ than & as]

He is stronger than Rustum (is) [Adj Phrase (C)]. គាត់ខ្លាំងជាង Rustum។

406. Certain words are used both as Prepositions and Conjucntions.

៤០៦. ពាក្យមួយចំនួនត្រូវបានគេប្រើជា Preposition ផងនិងត្រូវបានគេប្រើជា Conjunciton ផង។

| Preposition | Conjunction |
|---|---|
| Stay *till* Monday. | We shall stay here till (Conj) you (S) return (V). |

www.salarean.com

| | |
|---|---|
| ចូរស្នាក់នៅរហូតដល់ថ្ងៃច័ន្ទ។ | |
| I have not met him since (Prep) Monday (N).<br>ខ្ញុំមិនទាន់បានជួបគាត់ទេតាំងពីថ្ងៃច័ន្ទមក។ | We shall go *since* you desire it.<br>យើងនឹងទៅដោយសារអ្នកមានបំណងប្រាថ្នាអញ្ចឹងទៅហើយ។ |
| He died *for* his country.<br>គាត់ស្លាប់ដើម្បីជាតិ។ | I must stay here, for (Coordinating Conj) such is my duty.<br>ខ្ញុំត្រូវតែនៅទីនេះដោយសារ/ពីព្រោះនេះវាជាករណីយកិច្ចរបស់ខ្ញុំ។ |
| The day ran *after* the cat.<br>ឆ្កែដេញឆ្មា។ | We came *after* they had left.<br>យើងមកបន្ទាប់ពីពួកគេបានចាកចេញទៅ។ |
| To run after = ដេញ | |

| | |
|---|---|
| Everyday *but* Govind was present.<br>គេគ្រប់គ្នាលើកលែងតែ Govind ចេញសុទ្ធតែមានវត្តមាន។ | He tried, *but* did not succeed.<br>គាត់ខំប្រឹងដែរប៉ុន្តែមិនទទួលបានជោគជ័យ។ |
| but (prep) = except = លើកលែងតែ | but (Coordinating Conj) = ប៉ុន្តែ |
| He stood *before* the painting.<br>គាត់ឈរនៅខាងមុខផ្ទាំងគំនូរ។ | Look *before* you leap. (Proverb)<br>ចូរអ្នកមើលមុនលោត។ (គិតមុនគូ) |

www.salarean.com